# រដ្ឋលេខាធិការ

សូមគោរពមកដល់ ប្រជាពលរដ្ឋកាលីហ្វ័រនីញ៉ា

គ្មានសិទ្ធិអ្វីដែលធំធេងជាងសិទ្ធិដើម្បីបោះឆ្នោតឡើយ។  តាមរយៈការបោះឆ្នោត អ្នកអាចជួយជ្រើសរើសអ្នកដឹកនាំថ្នាក់មូលដ្ឋាន រដ្ឋ និងអ្នកដឹកនាំថ្នាក់ជាតិ និងធ្វើឲ្យប្រាកដថាគេបានឮសំឡេងរបស់អ្នក។  ការបោះឆ្នោតប្រធានាធិបតីជាបឋម កំពុងតែខិតជិតដល់ណាស់ហើយ។  សូមចូលរួមក្នុងសិទ្ធិជាមូលដ្ឋានបំផុតរបស់អ្នក ឋានៈជាពលរដ្ឋអាមេរិកមួយរូប។

ការណែនាំអ្នកបោះឆ្នោត អាចជួយអ្នកធ្វើការសំរេចឲ្យបានដឹងល្អ នៅថ្ងៃបោះឆ្នោត។  វាមានការវិភាគដោយមិនលំអៀង ការជជែកដែលពេញចិត្ត និងជំទាស់វិធានការសន្លឹកឆ្នោត សេចក្តីប្រកាសរបស់បេក្ខជន និងមានព័ត៌មានសំខាន់ៗផ្សេងទៀត។

អ្វីៗទាំងអស់ដែលបានបង្ហាញនៅកន្លែងនេះ គឺជាទីសំអាងសំរាប់អ្នក។ ការណែនាំនេះក៏មានតាមអ៊ិនទ័រណិតវ៉ិបសៃត៍របស់រដ្ឋលេខាធិការ នៅ: *www.voterguide.sos.ca.gov* ដែរ។

សូមចំណាយពេលអានព័ត៌មាននៅក្នុងការណែនាំនេះ ដោយប្រិតប្រៀង ដើម្បីត្រៀមខ្លួនសំរាប់ថ្ងៃបោះឆ្នោត។  បើអ្នកចង់ដឹងថាអ្នកណាកំពុងផ្តល់ហិរញ្ញវត្ថុ សំរាប់ការឃោសនានិមួយៗ អ្នកអាចស្រាវជ្រាវព័ត៌មានហិរញ្ញវត្ថុ ការឃោសនា នៅ: *powersearch.sos.ca.gov*។

បើអ្នកមានសំណួរអ្វីអំពីរបៀបបោះឆ្នោត ឬរបៀបចុះឈ្មោះបោះឆ្នោត អ្នកអាចទាក់ទងការិយាល័យនៃរដ្ឋលេខាធិការ ដោយទូរស័ព្ទទៅលេខឥតចេញថ្លៃ 1-888-345-4917។  អ្នកអាចមើលវ៉ិបសៃត៍របស់រដ្ឋលេខាធិការ នៅ *www.sos.ca.gov/county-elections-offices* ដើម្បីទទួលព័ត៌មានទំនាក់ទំនងនៃមន្ត្រីបោះឆ្នោតខោនធី នៅមូលដ្ឋានរបស់អ្នក។

យើងសូមអរគុណអ្នក សំរាប់ការប្តេជ្ញាចិត្តរបស់អ្នក ចំពោះអនាគតនៃរដ្ឋកាលីហ្វ័រនីញ៉ា។  ការបោះឆ្នោតប្រធានាធិបតីជាបឋម គឺថ្ងៃទី 7 ខែមិថុនា។  ឆ្នោតរបស់អ្នកគឺជាសារៈសំខាន់។  សូមចាំថាឆ្នោតរបស់អ្នកគឺជាសំឡេងរបស់អ្នក។  ចូរឲ្យបានឮ។  ចូរបោះឆ្នោត!